# ១. សេចក្តីផ្តើម

## ១.១ សង្ខេបគោលបំណងរបស់របាយការណ៍

ឆ្នាំសិក្សា២០០៣-០៤គឺជាដំណាក់ការសំខាន់មួយនៅក្នុងដំណើរការកំណែទំរង់វិស័យអប់រំ។ វាបានបង្ហាញពីការអនុវត្តន៍ផែនការអប់រំសំរាប់ទាំងអស់គ្នាក្នុងឆ្នាំដំបូង និងជាមូលដ្ឋានសំរាប់ពិនិត្យឡើងវិញនូវបទពិសោធក្នុងអំឡុងឆ្នាំ ២០០០-២០០៤ ដើម្បីធ្វើការកែលំអផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំ។

វត្ថុបំណងសំខាន់របស់របាយការណ៍ គឺធ្វើការវាយតំលៃលើការរីកចំរើននៃការសំរេចអោយបានតាមទិសដៅគោលនយោបាយ និង គោលដៅនានា ព្រមទាំងបង្ហាញពីយុទ្ធសាស្ត្រនិងកម្មវិធីសំខាន់នានាផងដែរ។ វត្ថុបំណងមួយទៀតនោះ គឺកំណត់ប្រសិទ្ធភាពនៃការប្រើប្រាស់យុទ្ធសាស្ត្រដែលមានស្រាប់ តាមរយៈការកែទំរង់ស្ថាប័ន និងកសាងសមត្ថភាព។

របាយការណ៍នេះផ្តោតទៅលើ ភាពរីកចំរើននៃការសំរេចបានតាមចំណុចដៅនៃ លទ្ធភាពទទួលបានការអប់រំ គុណភាពអប់រំ ការពង្រឹងស្ថាប័ន និង ហិរញ្ញវត្ថុ តាមរយៈការវិភាគផលប៉ះពាល់របស់សកម្មភាពគោលនយោបាយ និង កម្មវិធីនានា។ ការវាយតំលៃនេះក៏ផ្តោតលើ គោលដៅអភិវឌ្ឍន៏សហស្សវត្ស (MDGs)។

ដោយហេតុនេះហើយ របាយការណ៍បំពេញការងារវិស័យអប់រំឆ្នាំ២០០៤ នឹងផ្តោតលើការវិភាគនិន្នាការនានាក្នុងអំឡុងឆ្នាំ២០០០ដល់ ឆ្នាំ២០០៤ ដែលមានលក្ខណៈល្អជាងការធ្វើវិភាគតាមឆ្នាំនីមួយៗ ។

កំណែទំរង់វិស័យអប់រំក្នុងអំឡុងឆ្នាំ២០០០-២០០៤ : ការពិនិត្យឡើងវិញជាយុទ្ធសាស្ត្រ

- តំរែតំរង់ឡើងវិញ វិសាលភាពនៃការអប់រំនិងការបណ្តុះបណ្តាល ដើម្បីធានាអោយមានការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ កំណើនសេដ្ឋកិច្ច និងសង្គមដ៏ល្អមួយសំរាប់ប្រជាជនកម្ពុជា។
- កសាងគោលនយោបាយ និង យុទ្ធសាស្ត្របន្ថែមសំរាប់ការអប់រំនិងការបណ្តុះបណ្តាល ឬ អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានស្រាប់ ដើម្បីធានាអោយកាន់តែមានប្រសិទ្ធភាពជាងនេះ។
- នៅក្នុងបរិបទរបស់ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ទិសដៅជាក់លាក់សំរាប់ការពង្រីកសេវាអប់រំក៏រិតក្រោយមូលដ្ឋាន និងតួនាទីរបស់រដ្ឋាភិបាលក្នុងបញ្ហានេះ
- កែលំអភាពទាក់ទង គុណភាព និង ស្តង់ដានៃសេវាអប់រំអោយបានប្រសើរឡើង និង តួនាទីរបស់រដ្ឋាភិបាលក្នុងការធានា និងគ្រប់គ្រងលើស្តង់ដានានា។
- ការរំពឹងទុកនៃការបង្កើនចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ និងវិធានការនានាដើម្បីប្រមូលធនធានបន្ថែមពីផ្នែកឯកជន និងមាតាបិតាសិស្ស។
- មានវិធានការដើម្បីធានាថាការចំណាយលើវិស័យអប់រំមានឥទ្ធិពលជាអតិបរមា និងបន្តធានាអោយមានអ្នកពាក់ព័ន្ធ និង លទ្ធផល ព្រមទាំងប្រសិទ្ធភាពនៃការចំណាយ។

- បែបបទជំនួយពីខាងក្រៅដែលមានប្រសិទ្ធភាព ដើម្បីជួយសំរេចគោលបំណង និងចំណុចដៅនៃកំណែទំរង់វិស័យអប់រំ ។

## ១.២ ទិដ្ឋភាពនៃការរកឃើញ ក្នុងការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៣

របាយការណ៍នេះក៏ជាឱកាសមួយ ដើម្បីបញ្ជាក់ពីវិសាលភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្លើយតបទៅនឹងការរកឃើញដ៏ទូលំទូលាយក្នុងការពិនិត្យឡើងវិញរួមគ្នាកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៣។ នៅតាមវិស័យនីមួយៗ ក្រុមពិនិត្យឡើងវិញរួមគ្នាសំរាប់ឆ្នាំ២០០៣ បានរកឃើញនូវចំណុចមួយចំនួនដូចជា :

- វិធានការបន្ថែមដើម្បីកាត់បន្ថយឧបសគ្គចំណាយចំពោះការចូលរៀន រួមមានការពង្រីកសំភាររូបវ័ន្ត កាត់បន្ថយចំណាយក្រៅផ្លូវការ និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ។
- បន្តពង្រឹងយុទ្ធសាស្រ្តកែលំអ និងធានាគុណភាព តាមរយៈការរួមបញ្ចូលគ្នានូវសកម្មភាពនានា ការពិនិត្យតាមដានស្តង់ដាដែលមានលក្ខណៈតឹងរឹង និងកំណែទំរង់អភិបាលកិច្ច ។
- បន្តពង្រឹងការកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធសវនកម្ម ជាពិសេសដើម្បីធានាភាពអាចព្យាករណ៍បាន និងការប្រើប្រាស់ថវិកាបានកាន់តែប្រសើរឡើង ។
- ពិនិត្យឡើងវិញតុល្យភាពនៃការចំណាយលើវិស័យអប់រំទាំងអស់ រវាងអនុវិស័យនានា និងការចំណាយសំរាប់បុគ្គលិក និងមិនមែនបុគ្គលិក ដើម្បីធានាដល់ការកែទំរង់គោលនយោបាយ និង យុទ្ធសាស្រ្ត ។
- បញ្ចប់ការអភិវឌ្ឍន៍គោលនយោបាយ និងយុទ្ធសាស្រ្តសំរាប់ការពង្រីកមធ្យមសិក្សាទុតិយភូមិ ការបណ្តុះបណ្តាលជំនាញដល់យុវជន និង ឧត្តមសិក្សា ដោយគិតទាំងផ្នែកឯកជន និង ភាពជាដៃគូ ដែលមានការកំណត់ត្រឹមត្រូវ ។

ទាក់ទងនឹងបញ្ហាឆ្លងវិស័យគឺត្រូវអនុម័តច្បាប់អប់រំអោយបានទាន់ពេលវេលា ដែលបានចាប់ផ្តើមនៅដើមឆ្នាំ២០០៣ ដើម្បីធានាថាកម្មវិធីកំណែទំរង់វិស័យអប់រំត្រូវបានទ្រទ្រង់ដោយបទបញ្ញតិ គោលការណ៍ណែនាំប្រតិបត្តិដ៏ល្អប្រសើរ ព្រមទាំងសិទ្ធិអំណាច និង ការទទួលខុសត្រូវសមស្របនៅគ្រប់កំរិតនៃប្រព័ន្ធអប់រំ ។

## ១.៣ ការផ្សារភ្ជាប់ជាមួយនឹងការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ

ក្រសួងអប់រំ យុវជន និងកីឡាបានពិនិត្យឡើងវិញផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០០៤-០៨ ហើយបានបញ្ចប់រួចរាល់នៅខែកញ្ញា ឆ្នាំ២០០៤។ ដំណើរការរួមមាន ១) ឯកសារក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងផែនការការងារលើកដំបូងដែលបានឯកភាពជាមួយភាគីជាដៃគូនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៣ ២) ដំណើរការរបស់ក្រុមការងារបច្ចេកទេសកសាងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ដែលដឹកនាំដោយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ៣) ការវិភាគយុទ្ធសាស្រ្ត និងហិរញ្ញប្បទានទូលំទូលាយ ជាពិសេសសំរាប់ការអប់រំកំរិតក្រោយមូលដ្ឋាន និង៤) ការពិនិត្យឡើងវិញចំណុចដៅ និងអាំងឌីកាទ័របំពេញការងារវិស័យអប់រំ ។ *របាយការណ៍នេះផ្សារភ្ជាប់ទៅនឹងដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០០៤-០៨ និងឯកសារក្របខ័ណ្ឌ និងផែនការការងាររបស់កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ ។*

## រូបភាពទី១ : ការកើនឡើងនៃកាលានុវត្តភាពអប់រំ ឆ្នាំ ២០០០-២០០៤

